

# មីហ្សា

Let's Read
The Asia Foundation



មីហ្សាគឺជាកូនពៅនៅក្នុងគ្រួសារ។
រាល់ថ្ងៃ មីហ្សាតែងជួបជាមួយមនុស្សទាំងអស់ក្នុងគ្រួសារ។
ថ្ងៃនេះក៏មិនខុសគ្នាដែរ! នាងកំពុងតែជួបជាមួយពួកគេដូចថ្ងៃមុនៗ។



ដំបូង នាងបានដើរទៅរកលោកតារបស់នាង។ លោកតាបាន យកដៃខ្ទប់មាត់ ពេលដែលគាត់កំពុងក្អក។ មីហ្សា ក៏បាន ខ្ទប់មាត់របស់នាងដែរ។

លោកតាឃើញដូចនោះក៏និយាយ៖

- ល្អណាស់ ចៅស្រីសម្លាញ់ !.. ចៅក៏ត្រូវតែយកដៃខ្ទប់មាត់ របស់ចៅ នៅពេលដែលចៅកំពុងក្អកដែរ!..




បន្ទាប់មក មីហ្សាក៏ដើរទៅរកលោកយាយរបស់នាង។ លោកយាយកំពុងតែលាងដៃរបស់គាត់ជាមួយសាប៊ូ។ មីហ្សាក៏ចង់លាងដៃរបស់នាងដែរ។

ឃើញដូចនោះ លោកយាយក៏និយាយទៅមីហ្សាថា ៖

- ល្អណាស់ ចៅស្រីសម្លាញ់!.. ចៅក៏ត្រូវតែលាងដៃជាមួយសាប៊ូឲ្យបានញឹកញាប់ ដូចអ្វីដែលយាយកំពុងធ្វើនេះ!..



បន្ទាប់មកទៀត មីហ្សាបានដើរទៅរកឪពុករបស់នាង។
ឪពុករបស់មីហ្សាកំពុងជូតសម្អាតឥដ្ឋជាមួយថ្នាំសម្លាប់មេរោគ។
មីហ្សាក៏ចង់ជូតសម្អាតផ្ទះដែរ។
ឪពុកឃើញដូចនោះក៏និយាយទៅកាន់មីហ្សាថា ៖
- កូនស្រីសម្លាញ់!.. កូនក៏គួរតែជួយប៉ា សម្អាតកន្លែងដែលកូនបានលេងផងដែរ។



បន្ទាប់មកទៀត មីហ្សាបានដើរទៅក្បែរម្តាយរបស់នាង។ ម្តាយរបស់មីហ្សាកំពុងពាក់ម៉ាស់ និងរៀបចំធ្វើដំណើរចេញទៅក្រៅ។មីហ្សាក៏ចង់ពាក់ម៉ាស់ដែរ។

ម្តាយបាននិយាយទៅកាន់មីហ្សាថា ៖

- កូនស្រីសម្លាញ់ !.. ម៉ាក់ពាក់ម៉ាស់ ដោយសារតែពេលនេះមានមេរោគដ៏អាក្រក់កំពុងឆ្លង និងរីករាលដាលនៅក្នុងប្រទេសរបស់យើង។ដូច្នេះហើយកូនស្រីក៏ត្រូវតែពាក់ម៉ាស់ដែរ នៅពេលដែលកូនចេញទៅក្រៅ !..



បន្ទាប់មកទៀត មីហ្សាក៏បានដើរទៅក្បែរបងប្រុសច្បងរបស់នាង។

បងប្រុសច្បងកំពុងជូតទូរស័ព្ទរបស់គាត់ជាមួយនឹងកន្សែង។ មីហ្សាក៏ចង់ជូតទូរស័ព្ទដែរ។

បងប្រុសច្បងឃើញដូចនោះ ក៏និយាយទៅកាន់មីហ្សាថា ៖

- ប្អូនស្រីពៅសម្លាញ់!.. ប្អូនក៏ត្រូវតែជូតសម្អាតប្រដាប់ប្រដាលេងរបស់ប្អូនដែរ !..



បន្ទាប់មកទៀត, មីហ្សាក៏បានទៅជួបនឹងបងប្រុសទីពីររបស់នាង។ បងប្រុសទីពីររបស់មីហ្សាកំពុងខ្ពុរមាត់ ដើម្បីសម្អាតបំពងករបស់គាត់ ហើយក៏ចូលក្នុងបន្ទប់ទឹកស្ដោះទឹកខ្ពុរមាត់នោះចេញ។ មីហ្សាក៏ចង់ចូលបន្ទប់ទឹកដើម្បីស្ដោះទឹកមាត់ដែរ។ ភ្លាមនោះ បងប្រុសទីពីររបស់នាងបាននិយាយថា ៖

- ប្អូនស្រីពៅសម្លាញ់!.. ប្អូនត្រូវតែប្រើប្រាស់បន្ទប់ទឹក ប្រសិនបើប្អូនត្រូវការខាកស្ដោះ។ ប្អូនមិនត្រូវខាកស្ដោះនៅក្រៅផ្ទះ ឬក៏តាមផ្លូវនោះឡើយ។



បន្ទាប់មកទៀត មីហ្សាបានចូលទៅក្បែរបងស្រីទី២របស់នាង។ បងស្រីទី២របស់មីហ្សាទើបតែបញ្ចប់ការអធិដ្ឋានហើយបន្តការបួងសួង។ មីហ្សាក៏ចង់ធ្វើការបួងសួងដែរ។
បងស្រីទី២បាននិយាយទៅកាន់មីហ្សាថា ៖
- ប្អូនស្រីពៅសម្លាញ់!.. ប្អូនក៏គួរតែធ្វើការអធិដ្ឋាននិងបួងសួងដែរ ដើម្បីសុំឲ្យមានសុខភាពល្អ!.. ព្រះអាឡោះនឹងប្រទានពរដល់ប្អូន!..



មីហ្សាបានគិត ៖ ” ពួកគាត់ម្នាក់ៗសុទ្ធតែមានកិច្ចការធ្វើរៀងៗខ្លួន។ ខ្ញុំចង់ធ្វើដូចពួកគាត់ ”
បន្ទាប់ពីគិតដូច្នោះហើយ មីហ្សាក៏បានចាប់ផ្តើមរាប់ឡើងវិញនូវអ្វីដែលអ្នកទាំងអស់គ្នាបានធ្វើ។



តើបងស្រីទីពីររបស់នាងបានធ្វើអ្វី?
តើបងប្រុសទីពីររបស់នាងបានធ្វើអ្វី?
តើបងស្រីច្បងរបស់នាងបានធ្វើអ្វី?
តើបងប្រុសច្បងរបស់នាងបានធ្វើអ្វី?
តើម្ដាយរបស់នាងបានធ្វើអ្វី?
តើឪពុករបស់នាងបានធ្វើអ្វី?
តើលោកយាយរបស់នាងបានធ្វើអ្វី?
តើលោកតារបស់នាងបានធ្វើអ្វី?



មីហ្សាបានសម្រេចចិត្តថា ៖
ខ្ញុំនឹងធ្វើសកម្មភាពតាមពួកគាត់ទាំងអស់គ្នា ដើម្បីការពារខ្លួនខ្ញុំពីជំងឺឆ្លងនានា។



នៅពេលដែលអ្នកអានសៀវភៅនេះចប់ សូមឆ្លើយសំណួរខាងក្រោម៖

១. តើមីហ្សាគឺជានរណានៅក្នុងគ្រួសារ?
នាងគឺជាបងស្រីច្បង ឬជាប្អូនស្រីពៅ?

២. តើនៅក្នុងគ្រួសារមានសមាជិកប៉ុន្មាននាក់រួមទាំងមីហ្សា?
មានសមាជិកប្រាំបីនាក់ ឬប្រាំបួននាក់?

៣. តើនៅក្នុងគ្រួសារមានមនុស្សប្រុសចំនួនប៉ុន្មាននាក់?
មានបួននាក់ ឬប្រាំនាក់?

៤. តើនៅក្នុងគ្រួសារមានមនុស្សស្រីប៉ុន្មាននាក់?
មានបួននាក់ ឬប្រាំនាក់?

៥. តើអ្នកណាជាអ្នកដែលបានជូតសម្អាតផ្ទះ?

ម្តាយ ឬឪពុក?

៦. តើអ្នកណាជាអ្នករៀបខ្លួនចេញទៅក្រៅ?

ម្តាយ ឬឪពុក?

៧. រាល់សកម្មភាពទាំងអស់ដែលមីហ្សាចង់ធ្វើ តើសកម្មភាពមួយណាដែលអ្នកចង់ធ្វើជាងគេ?

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
, Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/

Contributing translators: Somey Chheang and Kem Lyheang